ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## ឯកឧត្តម ឈឿន ប៊ុណ្ណារ័ត្ន រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ

ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្ដីសោកស្ដាយជាពន់ពេក ក្រោយពីបានទទួលដំណឹងថា **ឧបាសិកា កូ យ៉ាន** ដែលត្រូវជាជីដូនរបស់ឯកឧត្តម ឈឿន ប៊ុណ្ណារ័ត្ន បានទទួលមរណភាព កាលពីថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ០០:៤៩ នាទីរំលងអាធ្រាត្រ ក្នុងជន្មាយុ ៩១ឆ្នាំ ដោយជរាពាធ។

ក្នុងវេលាពោរពេញដោយក្ដីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្ដែងនូវសេចក្ដីសោកស្ដាយ ស្រណោះ អាឡោះអាល័យជាទីបំផុត ចំពោះមរណភាពរបស់ **ឧបាសិកា កូ យ៉ាន** ដែលជាការបាត់បង់ជីដូន និងជីដូនទួតជាទីស្រឡាញ់ដ៏ឧត្ដុង្គឧត្ដម ប្រកបដោយព្រហ្មវិហារធម៌។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ **ឧបាសិកា កូ យ៉ាន** សូមបានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ ៕

ថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh